# គំនូរក្នុងរូងភ្នំ
# «ពើងដែក» ភ្នំគូលែន

ព្រះរាជាណាចក្រកម្ពុជា មានតំបន់ការពារធម្មជាតិជាច្រើនកន្លែងដែលត្រូវបានកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។ ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ជាផ្នែកមួយនៃតំបន់ការពារធម្មជាតិ ដែលមានផ្ទៃដីសរុបចំនួន ៣៧៥០០ ហិចតា និងមានតួនាទីសំខាន់ក្នុងការរក្សាលំនឹងបរិស្ថាននៅតំបន់អង្គរ ដោយសារប្រភពធនធានធម្មជាតិ ព្រៃឈើ ប្រភពទឹក និងជីវចម្រុះ ដែលមាននៅទីនោះ។ ភ្នំគូលែនជាទីតាំងប្រវត្តិសាស្ត្រដ៏សំខាន់មួយ ដែលបានរក្សាទុកនៅមរតកវប្បធម៌ជាច្រើនប្រភេទ និងជាអតីតរាជធានី នៃព្រះបាទជ័យវរ្ម័នទី២ ដែលព្រះអង្គបានធ្វើពិធីទេវរាជនៅលើភ្នំគូលែននោះ។ ប្រាសាទបុរាណជាច្រើន ចម្លាក់ក្នុងស្ទឹង ចម្លាក់តាមពើងនានា និងគំនូរតាមពើងថ្ម ជាច្រើនទីតាំងផងដែរ ។

គំនូរត្រូវបានមនុស្សប្រើប្រាស់ជាយូរណាស់មកហើយដូចជានៅរូងភ្នំ Lascaux ប្រទេសបារាំងដែលមានអាយុកាលចន្លោះ ៣៥០០០ឆ្នាំ-១០០០០ឆ្នាំ[១] ដែលជាសិល្បៈគំនូរក្នុងរូងភ្នំដ៏ចំណាស់។ ក្នុងនោះផងដែរក៏មានការសិក្សាពីតំបន់អាស៊ីផងដែរ ដូចជានៅប្រទេសថៃ ដែលបង្ហាញអំពីគំនូរពណ៌ក្រហមក្នុងរូងភ្នំ បង្ហាញអំពីមនុស្ស បាញ់ព្រួញ សត្វឆ្កែ ដែលគេកំណត់អាយុចន្លោះ៤០០០ មក២៥០០ ឆ្នាំមុនបច្ចុប្បន្ន។[២] ក្នុងនោះផងដែរក៏បាននិយាយអំពីគំនូរនៅរូងភ្នំក្នុងប្រទេសកម្ពុជា ដែលរកឃើញនៅភ្នំក្រវ៉ាញពើងគំនូរ និងភ្នំគូលែនពើងគំនូរ និងពើងតាខាប។ ក្នុងអត្ថបទមួយដែលសរសេរដោយលោកហេងថាន ក៏បានលើកមកបង្ហាញអំពីពើងដែលមានគំនូរមួយចំនួននៅតាមចង្កេះភ្នំគូលែន។[៣] ក្នុងអត្ថបទបណ្តាញពត៌មាន AMS ក៏ធ្លាប់បានផ្សាយ ដូចជាពើងតាខាប ពើងគំនូរ ល្អាងគំនូរនៅភ្នំក្រវាញ ពើងជ្រូក។[៤]

[១] https://hoopermuseum.earthsci.carleton.ca/2001_human_ka/genushomo18.html

[២] Noel Hidalgo Tan, 2014 Rock Art Research in Southeast Asia: A Synthesis, p76

[៣] ធ្នូ២០០៩-ធ្នូ២០១០, កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ, ទំព័រ៩០

[៤] https://ams.com.kh/khmercivilization/

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

ពើងដែរា ស្ថិតនៅភូមិទឹកលិច ឃុំបេងមាលា ស្រុកស្វាយលើ ខេត្តសៀមរាបដែលមានចំនុចនិយាមកា X= 413059 Y= 1493420 (រូបលេខ១)។[៥] ជាពើងថ្មធម្មជាតិមានទំហំប្រមាណ២០ម៉ែត្រ (រូបលេខ២) ស្ថិតនៅប្រហែល១គីឡូម៉ែត្រពីតំបន់យកថ្មសម្រាប់សាងសង់ប្រាសាទ។ គំនូរនៅពើងដែរា ត្រូវបានដឹងតាំងពីសម័យបារាំង ដោយមានស្នាមគំនូរជាច្រើននៅខាងក្រោមពើង ដែលមានគូរនៅផ្នែកខាងមុខ (រូបលេខ៣) និងចំហៀងដែលមានរូបដែរា រូបមនុស្ស រូបទឹក រូបសត្វ និងរូបមួយចំនួនទៀតពិបាកយល់។ ការហៅឈ្មោះពើងដែរានេះ ដោយឃើញមានរូបដៃមួយរាចេញម្រាមទាំង៥ និងមានរង្វង់មូលមួយនៅចំកណ្តាលនៃពើង ដែលមានទំហំប៉ុនបាតដៃយើងដែរ (រូបលេខ៤)។ រូបនេះគូរពីទឹកពណ៌ក្រហម នៅចំកណ្តាលរូបបាតដៃមានរូបរង្វង់មួយ យើងពុំដឹងថាអ្នកគូររូបនេះចង់បង្ហាញពីអ្វីទេ? ក្នុងនោះក៏មានបង្ហាញរូបគោ ឬសត្វចតុបាទណាមួយ ដែលគូរជាទឹកពណ៌ក្រហម និងស្នាកស្នាមគំនូរអំពីទឹកដោយពណ៌លឿងជាខ្សែឆូតៗ។ រូបនេះហាក់ដូចជាបង្ហាញអំពីសត្វគោក្នុងទឹក (រូបលេខ៥)។ ផ្នែកមួយទៀតក្នុង (រូបលេខ៦) មានរូបក្បាលគោ ឬទន្សោង២ក្បាល និងមានរូបធំមួយនៅចំកណ្តាលហាក់ដូចជារូបត្រី ឬជាដងខ្លួនសត្វអ្វីមួយ? រូបលេខ៧ មិនដឹងច្បាស់ថាជារូបអ្វី? រូបមួយគេគូរជាគំនូរឆូតៗ ហាក់ដូចជាសក់ ក៏ពុំដឹងថាជាអ្វីដែរ? រូបលេខ៨ ជារូបមនុស្ស ពណ៌ក្រហម លើកដៃទាំងពីរឡើងទៅលើ។ រូបលេខ៩ហាក់ដូចជារូបដើមឈើមួយ ឬជាសំណង់អ្វីមួយ ដែលធំនៅផ្នែកខាងលើ និងតូចនៅផ្នែកខាងលើ និងចុងស្រួច។ នៅមានស្នាកស្នាមគំនូរខ្លះៗ ទៀតដែលពិបាកក្នុងការកំណត់ម៉្យាងទៀតដោយសារការរលប់ និងអាយុកាលនៃគំនូរទាំងនេះ។ តើអាចទេថាទីតាំងពើងនេះ ជាទីជម្រករបស់មនុស្សបណ្តោះអាសន្ននៅពេលដែលពួកគេបរបាញ់សត្វ ឬធ្វើចម្ការ ឬចូលព្រៃរកអុសជាដើម ហើយជាការកំសាន្ត ឬក៏ជាកំណត់សម្គាល់អ្វីមួយរបស់ពួកគេក៏គូររូបទាំងនេះឡើង។

ទីតាំងគំនូរនេះមិនទាន់មានការសិក្សាស្រាវជ្រាវ បែបវិទ្យាសាស្ត្រនៅឡើយទេ។ តាមរយៈបច្ចេកទេសគូរនិងរបៀបគូរ យើងអាចដឹងថាគំនូរនេះពិតជាមានវ័យចំណាស់។ តើគំនូរទាំងនេះមានតាំងពីពេលណាមក?

---

[៥] ២០១៥, បញ្ជីបុរាណស្ថានក្នុងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ទំព័រ១៣៨

អត្ថបទដោយ៖ លឹម វណ្ណចន្ទ




រូបលេខ១ ផែនទីពើងដែក



រូបលេខ២ ពើងដែក

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបលេខ៣ គំនូរពើងដៃរាក្អែកខាងមុខ



រូបលេខ៤ រូបគំនូរដៃរា

អត្ថបទដោយ៖ លឹម វណ្ណាច័ន្ទ



រូបលេខ២៥ រូបគោ នឹងទឹក



រូបលេខ២៦

អត្ថបទដោយ៖ លឹម វណ្ណចន្ទ័



រូបលេខ២៧



រូបលេខ២៨



រូបលេខ២៩

អត្ថបទដោយ៖ លឹម វណ្ណចន័្ទ